# ព្រះរាជក្រឹត្យ

នស/រកត/០៦២១/៨៤៩

## ស្តីពី

## ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១** :

ត្រូវបានបង្កើត គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ សរសេរជាអក្សរកាត់ថា "គ.ក.រ" ដើម្បីដឹកនាំ និងសម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះមហាក្សត្រ

## ជំពូកទី២
## មុខងាររបស់ គ.ក.រ

**មាត្រា២** :

គ.ក.រ បំពេញមុខងារសំខាន់ៗដូចខាងក្រោម៖

- ដឹកនាំ គាំទ្រ និងសម្របសម្រួលការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំ និងអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល
- គាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល
- លើកសំណើជូនរាជរដ្ឋាភិបាលអនុម័តលើគោលនយោបាយ កម្មវិធី យុទ្ធសាស្ត្រ និងផែនការសកម្មភាពបម្រើឱ្យការកែទម្រង់រដ្ឋបាលសាធារណៈ
- លើកសំណើជូនរាជរដ្ឋាភិបាល ក្នុងការរៀបចំក្របខណ្ឌគតិយុត្ត សម្រាប់ការគាំទ្រដល់ការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល និងផ្តល់ជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការចូលរួមអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ពិនិត្យ និងអនុម័តសូចនាករសមិទ្ធកម្មគន្លឹះ និងដឹកនាំការងារត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារកែទម្រង់រដ្ឋបាលសាធារណៈជូនរាជរដ្ឋាភិបាល និងជំរុញការផ្សព្វផ្សាយសមិទ្ធផលនៃការងារកែទម្រង់រដ្ឋបាលសាធារណៈ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញការងារកែទម្រង់រដ្ឋបាលសាធារណៈ
- បំពេញការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល។

## ជំពូកទី៣
## សមាសភាព និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ គ.ក.រ

**មាត្រា៣** :

គ.ក.រ. មានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | ប្រធាន |
| ២. | រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ | អនុប្រធានប្រចាំការ |
| ៣. | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធាន |
| ៤. | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាតំណាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ១រូប | អនុប្រធាន |
| ៥. | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាតំណាងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ១រូប | អនុប្រធាន |
| ៦. | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាតំណាងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ១រូប | អនុប្រធាន |
| ៧. | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| ៨. | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| ៩. | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប | សមាជិក |
| ១០. | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | សមាជិក |
| ១១. | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប | សមាជិក |
| ១២. | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល ១រូប | សមាជិក |
| ១៣. | រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| ១៤. | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| ១៥. | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប | សមាជិក |
| ១៦. | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| ១៧. | រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | សមាជិក |
| ១៨. | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ១រូប | សមាជិក |
| ១៩. | រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប | សមាជិក |
| ២០. | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ១រូប | សមាជិក |
| ២១. | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ១រូប | សមាជិក |
| ២២. | រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| ២៣. | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ១រូប | សមាជិក |
| ២៤. | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១រូប | សមាជិក |
| ២៥. | រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប | សមាជិក |
| ២៦. | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ១រូប | សមាជិក |
| ២៧. | រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប | សមាជិក |
| ២៨. | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប | សមាជិក |
| ២៩. | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ១រូប | សមាជិក |
| ៣០. | រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៣១. | ប្រធានលេខាធិការដ្ឋាន គ.ក.វ. | សមាជិកអចិន្ត្រៃយ៍ |

ក្រៅពីសមាជិកខាងលើនេះ គ.ក.វ. អាចស្នើបន្ថែមសមាជិកជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធតាមការចាំបាច់។

ប្រធាន គ.ក.វ. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

អនុប្រធាន និងសមាជិក គ.ក.វ. ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន គ.ក.វ.។

## ជំពូកទី៤
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ គ.ក.វ

**មាត្រា៤** :

គ.ក.វ. ត្រូវប្រជុំរៀងរាល់ត្រីមាស។ កិច្ចប្រជុំនេះ ដឹកនាំដោយប្រធាន ឬអនុប្រធានប្រចាំការតាមការប្រគល់សិទ្ធិ។

ក្នុងករណីចាំបាច់ ប្រធាន គ.ក.វ. អាចមានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬតំណាងរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ចូលរួមប្រជុំ និងបំពេញការងារស្របតាមបទប្បញ្ញត្តិ ដែលមានក្នុងព្រះរាជក្រឹត្យនេះ។

គ.ក.រ. មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬ អ្នកជំនាញការជាតិ និងអន្តរជាតិ ចូលរួមប្រជុំ ក្នុងឋានៈជាសមាជិកសង្កេតការណ៍ ឬជាអ្នកផ្តល់យោបល់តាមការចាំបាច់។

គ.ក.រ. ត្រូវធ្វើរបាយការណ៍ប្រចាំឆមាសជូនប្រមុខរាជរដ្ឋាភិបាល។

គ.ក.រ. មានសិទ្ធិប្រើរូបសញ្ញា និងត្រារបស់ក្រសួងមុខងារសាធារណៈ ដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

**មាត្រា៥** :

គ.ក.រ. មានអនុគណៈកម្មាធិការនានា ដើម្បីគាំទ្រដល់ការបំពេញមុខងារដូចមានចែងក្នុងមាត្រា២ខាងលើ។

គ.ក.រ. មានលេខាធិការដ្ឋានជាសេនាធិការសម្រាប់គាំទ្រកិច្ចដំណើរការ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន និងអនុគណៈកម្មាធិការ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦** :

ក្រសួង ស្ថាប័នថ្នាក់ជាតិ ត្រូវរៀបចំបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន ដែលដឹកនាំដោយថ្នាក់ដឹកនាំជា អនុប្រធាន ឬសមាជិកគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន ត្រូវបង្កើតឡើងដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី។

**មាត្រា៧** :

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរាជធានី ខេត្ត ត្រូវបង្កើតឡើងដោយដីការបស់អភិបាលនៃគណៈអភិបាលសាមី។

## ជំពូកទី៥
## ធនធាន និងថវិការបស់ គ.ក.រ

**មាត្រា៨** :

ធនធាន និងថវិកាសម្រាប់ទ្រទ្រង់ដំណើរការនៃការងាររបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានប្រភពពីថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែកក្នុងថវិកាក្រសួងមុខងារសាធារណៈ។

ធនធានផ្សេងទៀត រួមមាន ថវិកា និងធនធានគាំទ្រផ្នែកសម្ភារៈ និងបច្ចេកទេសពីក្រសួង ស្ថាប័នដទៃរបស់រាជរដ្ឋាភិបាល កម្មវិធីកែទម្រង់ផ្សេងទៀត និង/ឬ ធនធាន និងថវិកាគាំទ្រផ្នែកសម្ភារៈ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ និងពីប្រភពស្របច្បាប់ដទៃទៀត។

ការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់ គ.ក.រ. ត្រូវអនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ ច័ន្ទ ១៤រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០២១

នរោត្តម សីហមុនី

នរោត្តម សីហមុនី

នស/រកត.០៦២១.៥៥៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ប្រាំ សុខា**